អាជ្ញាធរមីន

C.M.A.A

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

# របាយការណ៍
# ស្តីពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
# នៅខែកក្កដា ឆ្នាំ២០២៤

## សារតារ

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (CMVIS) បានបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយកាកបាទក្រហមកម្ពុជា ដែលគាំទ្រថវិកា ព្រមទាំងបច្ចេកទេសពីអង្គការជនពិការអន្តរជាតិបែលហ្ស៊ិក និងអង្គការយូនីសេហ្វ។

នៅដំណាច់ឆ្នាំ២០០៩ CMVIS ត្រូវបានផ្ទេរប្រគល់ពីកាកបាទក្រហមកម្ពុជា មកស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ក្នុងការប្រមូលទិន្នន័យ វិភាគទិន្នន័យ បកស្រាយទិន្នន័យ និងការចែកចាយទិន្នន័យជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម(ស.ផ.ស.) នៅក្នុងប្រទេសកម្ពុជា។

## ព័ត៌មានស្តីពីគ្រោះថ្នាក់ និងជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (មីន និងស.ផ.ស.)

### ១-ជនរងគ្រោះពីខែមករា ឆ្នាំ១៩៧៩ ដល់ខែកក្កដា ឆ្នាំ២០២៤

ចាប់ពីខែមករា ឆ្នាំ១៩៧៩ ដល់ខែកក្កដា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៦៥.០៧៤នាក់ ដែលបានកត់ត្រាដោយការិយាល័យ CMVIS ក្នុងនោះរួមមាន៖

- ជនរងគ្រោះដោយសារមីន ៥១.២០២នាក់(៧៩%) និងស.ផ.ស. ១៣.៨៧២នាក់(២១%)
- ជនរងគ្រោះស្លាប់ ១៩.៨៣១នាក់(៣០%) របួស ៣៦.១៤៨នាក់(៥៦%) និងពិការអវយវៈ ៩.០៩៥នាក់(១៤%)
- ជនរងគ្រោះជាបុរស ៥២.៦៩៨នាក់(៨១%) ក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៦.១២១នាក់(៩%) ស្ត្រី ៤.៧៩៦នាក់(៨%) ក្មេងស្រីអាយុក្រោម១៨ឆ្នាំ ១.៣៩៦នាក់(២%) និងជនរងគ្រោះមិនស្គាល់អត្តសញ្ញាណ ៦៣នាក់(០%)។

### ២- ឧប្បត្តិហេតុគ្រោះថ្នាក់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២៤ករណី ដែលតួលេខនេះមានការកើនឡើង ៤% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៣ករណី។

ក្នុងចំណោមឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២៤ករណីរួមមាន៖ ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១៥ករណី និងឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារស.ផ.ស. ៩ករណី។

### ៣- ជនរងគ្រោះពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៤

ចាប់ពីខែមករា ដល់ខែកក្កដា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣៧នាក់។ តួលេខនេះបានកើនឡើង ៦១% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០២៣ ដែលមានជនរងគ្រោះចំនួន ២៣នាក់។

ក្នុងចំណោមជនរងគ្រោះចំនួន ៣៧នាក់ រួមមាន៖

- ជនរងគ្រោះដោយសារមីន ១៨នាក់ និងជនរងគ្រោះដោយសារស.ផ.ស. ១៩នាក់
- ជនរងគ្រោះស្លាប់ ៩នាក់ របួស ២១នាក់ និងពិការអវយវៈ ៧នាក់
- ជនរងគ្រោះជាបុរស ២៣នាក់ ជាស្ត្រី ២នាក់ ជាក្មេងប្រុសអាយុក្រោម១៨ឆ្នាំ ៩នាក់ និងជាក្មេងស្រីអាយុក្រោម១៨ឆ្នាំ ៣នាក់។

## ៤- ឧប្បត្តិហេតុគ្រោះថ្នាក់ក្នុងខែកក្កដា ឆ្នាំ២០២៤

នៅខែកក្កដា ឆ្នាំ២០២៤ មានឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ៣ករណី បានកើតឡើងនៅខេត្តព្រះវិហារ ខេត្តប៉ៃលិន ខេត្តបាត់ដំបង និងខេត្តត្បូងឃ្មុំ។ តួលេខនេះបានកើនឡើង ៥០% បើប្រៀបធៀបនឹងខែកក្កដា ឆ្នាំ២០២៣ ដែលមានឧប្បត្តិហេតុគ្រោះថ្នាក់ចំនួន ២ករណី។

ព័ត៌មានអំពីឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅខែកក្កដា ឆ្នាំ២០២៤

- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ១ករណី កើតឡើងនៅលើដីចម្ការ
- ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារមីន ២ករណី កើតឡើងនៅតំបន់ផ្តល់អនុផលព្រៃឈើ។

## ៥- ជនរងគ្រោះក្នុងខែកក្កដា ឆ្នាំ២០២៤

នៅខែកក្កដា ឆ្នាំ២០២៤ មានជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះចំនួន ២នាក់។ តួលេខនេះដូចគ្នានឹងខែកក្កដា ឆ្នាំ២០២៣។

ព័ត៌មានអំពីជនរងគ្រោះចំនួន ២នាក់ រួមមាន៖

- ជនរងគ្រោះជាបុរស ២នាក់ បានរងគ្រោះដោយសារមីន ២នាក់
- ជនរងគ្រោះពិការអវយវៈ ១នាក់ និងស្លាប់ ១នាក់
- សកម្មភាពនៅពេលគ្រោះថ្នាក់គឺ៖ ការធ្វើកសិកម្ម ១នាក់ និងការរកស្បៀងអាហារ ១នាក់។

## ៦- ផលប៉ះពាល់ពីតំបន់គ្រោះថ្នាក់ពីខែមករា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤ (ជនរងគ្រោះ ៦៩នាក់)

- ខេត្តចំនួន ៥ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៩៧% នៃជនរងគ្រោះសរុប
- ស្រុកចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៦៧% នៃជនរងគ្រោះសរុប
- ឃុំចំនួន ១០ ដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតមានជនរងគ្រោះ ៥៤% នៃជនរងគ្រោះសរុប។

*ព័ត៌មានលម្អិត សូមមើលទំព័រទី៧*

ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

## ទីតាំងគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅខែកក្កដា ឆ្នាំ២០២៤
## ឧប្បត្តិហេតុ ៣ករណី ជនរងគ្រោះ ២នាក់




Produced by CMVIS, Aug 2024

ព័ត៌មានលម្អិតទាក់ទងនឹងព័ត៌មានអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ សូមទំនាក់ទំនងមកការិយាល័យ CMVIS តាមរយៈអាស័យដ្ឋានអ៊ីម៉ែល: ketya@cmaa.gov.kh

# របាយការណ៍ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះពីខែមករា ឆ្នាំ២០២១ ដល់ខែកក្កដា ឆ្នាំ២០២៤

| | ជនរងគ្រោះតាមខែ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឆ្នាំ/ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
| **2021** | **6** | **5** | **2** | **8** | **5** | **0** | **4** | **3** | **1** | **8** | **0** | **2** | **44** |
| *ការបូកបណ្តាក់ ឆ្នាំ2021* | *6* | *11* | *13* | *21* | *26* | *26* | *30* | *33* | *34* | *42* | *42* | *44* | |
| **2022** | **11** | **9** | **7** | **7** | **5** | **1** | **0** | **0** | **0** | **0** | **0** | **1** | **41** |
| *ការបូកបណ្តាក់ ឆ្នាំ2022* | 11 | 20 | 27 | 34 | 39 | 40 | 40 | 40 | 40 | 40 | 40 | 41 | |
| *ការប្រែប្រួលភាគរយ 2021 ធៀប 2022* | 83 | 82 | 108 | 62 | 50 | 54 | 33 | 21 | 18 | -5 | -5 | -7 | |
| **2023** | **3** | **5** | **4** | **0** | **7** | **2** | **2** | **3** | **1** | **2** | **1** | **2** | **32** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2022* | -8 | -4 | -3 | -7 | 2 | 1 | 2 | 3 | 1 | 2 | 1 | 1 | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2022* | -73 | -44 | -43 | -100 | 40 | 100 | 100 | 100 | 100 | 100 | 100 | 100 | |
| *ការបូកបណ្តាក់ ឆ្នាំ2023* | ***3*** | ***8*** | ***12*** | ***12*** | ***19*** | ***21*** | ***23*** | ***26*** | ***27*** | ***29*** | ***30*** | ***32*** | |
| *ការប្រែប្រួលភាគរយ 2022 ធៀប 2023* | -73 | -60 | -56 | -65 | -51 | -48 | -43 | -35 | -33 | -28 | -25 | -22 | |
| **2024** | **3** | **3** | **5** | **12** | **7** | **5** | **2** | | | | | | **37** |
| *ការប្រែប្រួលតួលេខតាមខែធៀប 2023* | 0 | -2 | 1 | 12 | 0 | 3 | 0 | | | | | | |
| *ការប្រែប្រួលភាគរយតាមខែធៀប 2023* | 0 | -40 | 25 | 100 | 0 | 150 | 0 | | | | | | |
| *ការបូកបណ្តាក់ ឆ្នាំ2024* | ***3*** | 6 | ***11*** | ***23*** | ***30*** | ***35*** | ***37*** | | | | | | |
| *ការប្រែប្រួលភាគរយ 2023 ធៀប 2024* | 0 | -25 | -8 | 92 | 58 | 67 | 61 | | | | | | |

ចំណាំៈ តួលេខជនរងគ្រោះសម្រាប់ខែបន្តបន្ទាប់ទៀត នៃដំណើរការប្រមូលទិន្នន័យនឹងស្រាវជ្រាវឱ្យទាន់ពេលវេលា



# ជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤

## រាជធានីខេត្តត្រូវបានតម្រៀបតាមលំដាប់ចុះនៃផលបូកសរុបជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ក្នុងឆ្នាំ២០២៣ និងឆ្នាំ២០២៤

| | មករា23 | កុម្ភៈ23 | មីនា23 | មេសា23 | ឧសភា23 | មិថុនា23 | កក្កដា23 | សីហា23 | កញ្ញា23 | តុលា23 | វិច្ឆិកា 23 | ធ្នូ23 | សរុប2023 | មករា24 | កុម្ភៈ24 | មីនា24 | មេសា24 | ឧសភា24 | មិថុនា24 | កក្កដា24 | សីហា24 | កញ្ញា24 | តុលា24 | វិច្ឆិកា 24 | ធ្នូ24 | សរុប2024 | សរុប | ការបូកបណ្តាក់លើសរុប | ភាគរយនៃសរុប | ការបូកបណ្តាក់លើភាគរយសរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះខេត្ត | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | ចំនួន | **ចំនួន** | **2023-2024** | | | |
| បាត់ដំបង | 0 | 0 | 0 | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 2 | **6** | 0 | 1 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **3** | **9** | 9 | 13 | 13 |
| ឧត្តរមានជ័យ | 0 | 1 | 1 | 0 | 1 | 0 | 0 | 1 | 0 | 0 | 1 | 0 | **5** | 0 | 0 | 3 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 18 | 13 | 26 |
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 | 3 | 0 | 1 | 0 | 0 | 1 | 0 | 0 | **5** | 0 | 2 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | **9** | 27 | 13 | 39 |
| មណ្ឌលគិរី | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 6 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **6** | **6** | 33 | 8.7 | 48 |
| ព្រះវិហារ | 1 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 2 | 2 | 0 | 0 | 0 | 0 | 0 | 0 | **4** | **6** | 39 | 8.7 | 57 |
| ពោធិ៍សាត់ | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 3 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 44 | 7.2 | 64 |
| កំពង់ធំ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 49 | 7.2 | 71 |
| កំពង់ឆ្នាំង | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | **4** | **5** | 54 | 7.2 | 78 |
| ត្បូងឃ្មុំ | 0 | 0 | 0 | 0 | 0 | 2 | 0 | 0 | 0 | 1 | 0 | 0 | **3** | 0 | 0 | 0 | 0 | 0 | 1 | 1 | 0 | 0 | 0 | 0 | 0 | **2** | **5** | 59 | 7.2 | 86 |
| រតនគិរី | 0 | 3 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | **4** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **4** | 63 | 5.8 | 91 |
| សៀមរាប | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **2** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **2** | 65 | 2.9 | 94 |
| ព្រះសីហនុ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | **1** | 66 | 1.4 | 96 |
| តាកែវ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 67 | 1.4 | 97 |
| ក្រចេះ | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **1** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **1** | 68 | 1.4 | 99 |
| ប៉ៃលិន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 1 | 0 | 0 | 0 | 0 | 0 | **1** | **1** | 69 | 1.4 | 100 |
| កំពត | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| កំពង់ស្ពឺ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| កំពង់ចាម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| កណ្តាល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| កោះកុង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| ព្រៃវែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| ស្ទឹងត្រែង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| ស្វាយរៀង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| កែប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| ភ្នំពេញ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | **0** | **0** | 69 | 0 | 100 |
| **សរុប** | 3 | 5 | 4 | 0 | 7 | 2 | 2 | 3 | 1 | 2 | 1 | 2 | **32** | 3 | 3 | 5 | 12 | 7 | 5 | 2 | 0 | 0 | 0 | 0 | 0 | **37** | **69** | | | |



## ខេត្តចំនួន 5 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤

| លំដាប់ | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 7 | 2 | **9** | 9 |
| 2 | បាត់ដំបង | 7 | 2 | **9** | 18 |
| 3 | ឧត្តរមានជ័យ | 8 | 1 | **9** | 27 |
| 4 | មណ្ឌលគិរី | 0 | 6 | **6** | 33 |
| 5 | ព្រះវិហារ | 5 | 1 | **6** | 39 |

## ស្រុកចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤

| លំដាប់ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|
| 1 | ជាំក្សាន្ត | ព្រះវិហារ | 5 | 1 | **6** | 6 |
| 2 | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 12 |
| 3 | អន្លង់វែង | ឧត្តរមានជ័យ | 5 | 1 | **6** | 18 |
| 4 | សំឡូត | បាត់ដំបង | 5 | 0 | **5** | 23 |
| 5 | វាលវែង | ពោធិ៍សាត់ | 5 | 0 | **5** | 28 |
| 6 | ស្នោង | កំពង់ធំ | 0 | 4 | **4** | 32 |
| 7 | អូរយ៉ាដាវ | រតនគិរី | 1 | 3 | **4** | 36 |
| 8 | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 40 |
| 9 | អូរជ្រៅ | បន្ទាយមានជ័យ | 3 | 0 | **3** | 43 |
| 10 | ថ្មពួក | បន្ទាយមានជ័យ | 3 | 0 | **3** | 46 |

## ឃុំចំនួន 10 ទទួលរងឥទ្ធិពលខ្លាំងជាងគេ ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

ត្រូវបានតម្រៀបតាមលំដាប់ចុះ នៃផលបូកសរុបជនរងគ្រោះ
ពីខែមករា ឆ្នាំ២០២៣ ដល់ខែកក្កដា ឆ្នាំ២០២៤

| លំដាប់ | ឃុំ | ស្រុក | ខេត្ត | អ្នករងគ្រោះ មីន | អ្នករងគ្រោះ សំណល់ជាតិផ្ទុះពីសង្គ្រាម | ផលបូកសរុប អ្នករងគ្រោះ | ការបូកបណ្តាក់ លើផលបូកសរុប |
|---|---|---|---|---|---|---|---|
| 1 | ត្រពាំងប្រិយ៍ | អន្លង់វែង | ឧត្តរមានជ័យ | 5 | 1 | **6** | 6 |
| 2 | រមនា | សែនមនោរម្យ | មណ្ឌលគិរី | 0 | 6 | **6** | 12 |
| 3 | ធ្នុកទ្រូ | បរិបូណ៌ | កំពង់ឆ្នាំង | 0 | 4 | **4** | 16 |
| 4 | ថ្មដា | វាលវែង | ពោធិ៍សាត់ | 4 | 0 | **4** | 20 |
| 5 | រុងរឿង | ស្នោង | កំពង់ធំ | 0 | 4 | **4** | 24 |
| 6 | យ៉ាទុង | អូរយ៉ាដាវ | រតនគិរី | 0 | 3 | **3** | 27 |
| 7 | អូរបីជាន់ | អូរជ្រៅ | បន្ទាយមានជ័យ | 3 | 0 | **3** | 30 |
| 8 | គោករមៀត | ថ្មពួក | បន្ទាយមានជ័យ | 3 | 0 | **3** | 33 |
| 9 | មរកត | ជាំក្សាន្ត | ព្រះវិហារ | 1 | 1 | **2** | 35 |
| 10 | ទឹកក្រហម | ជាំក្សាន្ត | ព្រះវិហារ | 2 | 0 | **2** | 37 |

# ការផ្ទុះបញ្ចាំងទូទៅលើជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេលៈ មករា ឆ្នាំ២០២៣ - កក្កដា ឆ្នាំ២០២៤

ចំនួនសរុបនៃជនរងគ្រោះក្នុងអំឡុងពេលរាយការណ៍ៈ ៦៩










## ការផ្ទុះបញ្ចាំងទូទៅលើករណីរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ












ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន នៅ កម្ពុជា

អំឡុងពេលៈ ខែមករា ឆ្នាំ២០២៣ - ខែកក្កដា ឆ្នាំ២០២៤

ចំនួនសរុបនៃជនរងគ្រោះ ក្នុងអំឡុងពេលរាយការណ៍ៈ ៦៩

## សកម្មភាពដែលបណ្តាលឱ្យគ្រោះថ្នាក់យុទ្ធភណ្ឌគ្រឿងផ្ទុះ បែងចែកទៅតាមប្រភេទជនរងគ្រោះ

| បុរស | ស្ត្រី | ក្មេង | សរុប |
|---|---|---|---|
| 48 | 3 | 18 | 69 |




## សកម្មភាពរបស់ជនរងគ្រោះនៅពេលដែលគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

### សកម្មភាពដែលបណ្តាលឱ្យផ្ទុះមីន




### សកម្មភាពដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម




## ឧប្បត្តិហេតុគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ តាមលក្ខណៈភូមិសាស្ត្រដី

### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះមីន




### លក្ខណៈភូមិសាស្ត្រដីដែលបណ្តាលឱ្យផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម

